**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :..១៧៥...អនក្រ.បក**

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតគណៈកម្មាធិការត្រួតពិនិត្យនិងវាយតម្លៃចំណូលមិនមែនសារពើពន្ធ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១.-**

ត្រូវបានបង្កើត គណៈកម្មាធិការត្រួតពិនិត្យនិងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ដែលសរសេរជាអក្សរកាត់ថា “គ.ម.ព.” ដើម្បីពង្រឹងនិងបង្កើន ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នៃការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃលើការប្រមូលនិងការកៀរគរចំណូលមិនមែនសារពើពន្ធ។

## ជំពូកទី២
## សមាសភាពនិងភារកិច្ច

**មាត្រា២.-**

គ.ម.ព. មានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- រដ្ឋលេខាធិការទទួលបន្ទុកគ្រប់គ្រងនិងប្រមូលចំណូលមិនមែនសារពើពន្ធ នៃក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ | សមាជិក |
| ៤- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៥- អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៦- អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៧- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៨- អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៩- អគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១០- អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១១- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១២- អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៣- អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៤- អគ្គាធិការនៃអគ្គាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១៥- អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ គ.ម.ព. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣.-**

គ.ម.ព. មានភារកិច្ច ដូចតទៅ÷

- តាមដានការអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ លើសកម្មភាពនិងសូចនាករទាំងអស់ ពាក់ព័ន្ធការប្រមូលចំណូលមិនមែនសារពើពន្ធ ដែលត្រូវបានកំណត់ដោយគោលនយោបាយនិងយុទ្ធសាស្ត្រជាធរមាន រួមទាំងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម
- ជំរុញនិងផ្តល់ការណែនាំ ដល់ក្រសួង ស្ថាប័ននិងអង្គភាពពាក់ព័ន្ធ លើការអនុវត្តផែនការសកម្មភាព នៃការប្រមូលចំណូលមិនមែនសារពើពន្ធ ឱ្យសម្រេចបានតាមទិសដៅនិងទាន់ពេល ស្របតាមគោលនយោបាយនិងយុទ្ធសាស្ត្រជាធរមាន រួមទាំងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម
- ដឹកនាំ សម្របសម្រួល និងចាត់វិធានការជាក់ស្តែង ចំពោះការងារតឹងទារបំណុលមិនមែនសារពើពន្ធ
- រៀបចំ បូកសរុបរបាយការណ៍ និងវាយតម្លៃ លើវឌ្ឍនភាពប្រចាំឆមាស និងប្រចាំឆ្នាំ នៃការអនុវត្តផែនការសកម្មភាពកៀរគរចំណូលនិងតឹងទារបំណុលមិនមែនសារពើពន្ធ ជូនប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៤.-**

ក្រសួង ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវចាត់តាំងរដ្ឋលេខាធិការ មួយរូប ដើម្បីចូលរួមជាសមាជិក គ.ម.ពា. ដែលត្រូវទទួលបន្ទុកគ្រប់គ្រង ត្រួតពិនិត្យ តាមដាន និងបូកសរុបការប្រមូល ការកត់ត្រា ការកៀរគរចំណូល និងការចាត់វិធានការតឹងទារបំណុល នៅក្នុងក្របខណ្ឌ នៃសមត្ថកិច្ច របស់សាមីក្រសួង ស្ថាប័ន។

រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលប្រមូលចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំនិងបូកសរុបរបាយការណ៍ប្រចាំត្រីមាស ឆមាស និងឆ្នាំ ពាក់ព័ន្ធការប្រមូលចំណូលមិនមែនសារពើពន្ធ និងការតឹងទារបំណុល មិនមែនសារពើពន្ធ របស់សាមីក្រសួង ស្ថាប័ន ដើម្បីផ្ញើជូន គ.ម.ពា. ពិនិត្យ តាមដាន បូកសរុប វាយតម្លៃ និងស្នើសុំវិធានការពីប្រមុខរាជរដ្ឋាភិបាល។

រដ្ឋលេខាធិការទទួលបន្ទុកគ្រប់គ្រងនិងប្រមូលចំណូលមិនមែនសារពើពន្ធ នៃសាមីក្រសួង ស្ថាប័ននីមួយៗ មានអង្គភាពហិរញ្ញវត្ថុដែលទទួលបន្ទុកកត់ត្រាការប្រមូលចំណូល រួមទាំងរដ្ឋទេយ្យករចំណូលនិងមន្ត្រីពាក់ព័ន្ធ ប្រចាំសាមីក្រសួង ស្ថាប័ន ជាសេនាធិការ ក្នុងការបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

ក្រសួង ស្ថាប័នដែលប្រមូលចំណូលមិនមែនសារពើពន្ធ មានកាតព្វកិច្ចផ្តល់ជាផ្លូវការ នូវរាល់កិច្ចសន្យា កិច្ចព្រមព្រៀង អាជ្ញាប័ណ្ណ និងលិខិតគតិយុត្ត ដែលមានកម្មវត្ថុបង្កើតចំណូលមិនមែនសារពើពន្ធ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេល ៦០ ថ្ងៃ ក្រោយអនុក្រឹត្យនេះ ចូលជាធរមាន ចំពោះកិច្ចសន្យា កិច្ចព្រមព្រៀង អាជ្ញាប័ណ្ណ និងលិខិតគតិយុត្ត ដែលត្រូវបានបង្កើតរួចហើយ និងក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីកិច្ចសន្យា កិច្ចព្រមព្រៀង អាជ្ញាប័ណ្ណ និងលិខិតគតិយុត្ត ត្រូវបានចុះហត្ថលេខា ចំពោះកិច្ចសន្យា កិច្ចព្រមព្រៀង អាជ្ញាប័ណ្ណ និងលិខិតគតិយុត្ត ដែលបង្កើតឡើងក្រោយការចូលជាធរមាននៃអនុក្រឹត្យនេះ។

**ជំពូកទី៣**

**ដំណើរការការងារ**

**មាត្រា៥.-**

សមាសភាពនៃ គ.ម.ពា. ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានកោះអញ្ជើញ និងដឹកនាំការប្រជុំ គ.ម.ពា. តាមការប្រគល់សិទ្ធិរបស់ប្រធាន។

ប្រធាន គ.ម.ពា. អាចអញ្ជើញមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមពិគ្រោះយោបល់តាមការចាំបាច់។

គ.ម.ពា. មានរបបប្រជុំសាមញ្ញ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំជាវិសាមញ្ញ តាមការចាំបាច់។

គ.ម.ពា. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៦.-**

គ.ម.ពា. មានលេខាធិការដ្ឋានមួយ ជាសេនាធិការ ក្នុងការបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន។

អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារ ជាលេខាធិការដ្ឋាន របស់ គ.ម.ពា. ដោយមានជំនួយពីអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានភារកិច្ច ដូចតទៅ÷

- រៀបចំនិងសម្របសម្រួលការងារប្រជុំរបស់ គ.ម.ពា. តាមការណែនាំរបស់ប្រធាន គ.ម.ពា.
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន ក្នុងការតាមដាន និងត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពនៃការប្រមូលចំណូលមិនមែនសារពើពន្ធ ស្របតាមគោលនយោបាយនិងយុទ្ធសាស្ត្រជាធរមាន រួមទាំងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម

- ដឹកនាំ និងសម្របសម្រួល ជាមួយដៃគូអភិវឌ្ឍន៍ លើការងារស្រាវជ្រាវពាក់ព័ន្ធការប្រមូលចំណូលមិនមែនសារពើពន្ធ
- រៀបចំ ពិនិត្យ តាមដាន សម្របសម្រួល និងបូកសរុបរបាយការណ៍វឌ្ឍនភាព ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ នៃការអនុវត្តផែនការសកម្មភាពកៀរគរចំណូលនិងតឹងទារបំណុលមិនមែនសារពើពន្ធ ជូន គ.ម.ព.
- រៀបចំអនុសាសន៍ ជូន គ.ម.ព. ស្តីពីការជំរុញការអនុវត្តផែនការសកម្មភាពកៀរគរចំណូលនិងតឹងទារបំណុលមិនមែនសារពើពន្ធឱ្យស្របតាមសូចនាករដែលបានកំណត់
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ប្រធាន គ.ម.ព.។

**មាត្រា៧.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិចេញប្រកាសនិងលិខិតបទដ្ឋានគតិយុត្តចាំបាច់ផ្សេងទៀត ដើម្បីអនុវត្តអនុក្រឹត្យនេះ រួមទាំងវិធាននិងនីតិវិធី នៃការតឹងទារបំណុលមិនមែនសារពើពន្ធ។

**ជំពូកទី៤**

**អវសានប្បញ្ញត្តិ**

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ